ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងរដ្ឋប្បវេណីលេខៈ ៥៨០
ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០
សាលក្រមលេខៈ ២៣ (ថ)
ចុះថ្ងៃទី២១ /មិថុនា /២០២១

# នាមនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តកណ្ដាលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់
នៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២១ ដោយមានសមាសភាពៈ

**ចៅក្រមជំនុំជម្រះ**

- លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

- លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

- ដើមចោទឈ្មោះ [redacted] ម៉ៅ ភេទស្រី អាយុ ៦២ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន [redacted]

- ចុងចម្លើយឈ្មោះ [redacted] សុខលីម ភេទប្រុស អាយុ ៤៧ឆ្នាំ មានទីលំនៅបច្ចុប្បន្ននៅ [redacted] ដោយមានលោក [redacted] មករា, លោក [redacted] សូរិយា និង លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ ។

## អង្គហេតុ និងចំណុចវិវាទ

១. សាលក្រមដែលទាមទារដោយដើមចោទ

ប្ដឹងសុំឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារដូចខាងក្រោមៈ

១.១.សុំរំលាយកិច្ចសន្យាទិញ-លក់ដី ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៩ ដែលមានដីទំហំ ៤៥៣២ ម៉ែត្រការ៉េ ដែលមានព្រំប្រទល់ខាងជើងទល់នឹងក្បាលដីលេខ ៥៤១ ខាងត្បូងទល់នឹងព្រែក ខាងលិចទល់នឹងផ្លូវ ខាងកើតទល់ក្បាលដីលេខ៥៤៦ ស្ថិតនៅភូមិពាមសាលា ឃុំស្អាងភ្នំ ស្រុកស្អាង ខេត្តកណ្ដាល។

១.២.សុំទាមទារសំណងជម្ងឺចិត្តចំនួន ៣៥០០០$ (បីម៉ឺនប្រាំពាន់) ដុល្លារអាមេរិក។

១.៣.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយ។

២. ការពន្យល់ត្រួសៗអំពីរឿងក្ដី

នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៩ ឈ្មោះ [redacted] សុខលីម បានព្រមព្រៀងទិញដីរបស់ខ្ញុំទំហំ ៤៥៣២ (បួនពាន់ប្រាំរយសាមសិបពីរ) ម៉ែត្រការ៉េ ស្ថិតនៅភូមិពាមសាលា ឃុំស្អាងភ្នំ ស្រុកស្អាង ខេត្តកណ្ដាល ក្នុងតម្លៃ ៣០$ (សាមសិប) ដុល្លារអាមេរិក ក្នុងមួយម៉ែត្រការ៉េ ដោយបានកក់ប្រាក់ចំនួនពីរដំណាក់កាលសរុបចំនួន ៣៥០០០$ (បីម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ឱ្យទៅដើមចោទឈ្មោះ [redacted] ម៉ៅ ដោយបានធ្វើកិច្ចសន្យាប្រគល់ទទួលប្រាក់ត្រឹមត្រូវ ហើយភាគីអ្នកទិញបានសន្យាប្រគល់ប្រាក់គ្រប់ចំនួននៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩។ លុះដល់ថ្ងៃកំណត់ហើយ ភាគីអ្នកទិញមិនបានប្រគល់ប្រាក់បង្គ្រប់ថ្លៃទិញដីខាងលើទៅឱ្យភាគីដើមចោទឈ្មោះ [redacted] ម៉ៅ ឡើយ។ ដូច្នេះហើយទើបដើមចោទបានដាក់ពាក្យបណ្ដឹងសុំរំលាយកិច្ចសន្យាខាងលើនេះចោល។

ចំពោះកិច្ចសន្យាទិញ លក់ដី ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៩ ភាគីដើមចោទ និងភាគីចុងចម្លើយបានព្រមព្រៀងគ្នាបង្កើតកិច្ចសន្យាទិញលក់ដីមួយកន្លែងដែលមានក្បាលដីលេខ ៥៤៥ ទំហំសរុប ៤៥៣២ (បួនពាន់ប្រាំរយសាមសិនពីរ) ម៉ែត្រការ៉េ ក្នុងតម្លៃ ១ម៉ែត្រការ៉េ ៣០$ (សាមសិប) ដុល្លារអាមេរិក ដែលស្ថិតនៅក្នុងភូមិពាមសាលា ឃុំស្អាងភ្នំ ស្រុកស្អាង ខេត្តកណ្ដាល ដោយភាគីចុងចម្លើយបានធ្វើការកក់ប្រាក់

Scanned with CamScanner

ចំនួន ១៥០០០$ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក នៅក្នុងកិច្ចសន្យាលក់នោះ ហើយថែមទាំងបានកំណត់ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៩ ប្រគល់ប្រាក់គ្រប់ចំនួនទៅឱ្យភាគីដើមចោទ។

ចំពោះលិខិតប្រគល់ទទួលប្រាក់ថ្លៃលក់ទិញអចលនវត្ថុ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ ភាគីចុងចម្លើយបានប្រគល់ប្រាក់កក់បន្ថែមចំនួន ២០០០០$ (ពីរម៉ឺន) ដុល្លារអាមេរិក ឱ្យភាគីដើមចោទ ដំណាក់កាលទី២ ភាគីទាំងសងខាងបានព្រមព្រៀងគ្នាបន្ថែមទៀតថា ភាគីអ្នកទិញត្រូវប្រគល់ប្រាក់បង្គ្រប់នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩ ទេ ត្រូវជាច់ប្រាកកក់ជាស្ថាពរ។

ការមិនបំពេញកាតព្វកិច្ចរបស់ភាគីចុងចម្លើយក្នុងការបង់ប្រាក់គ្រប់ចំនួន ជូនមកភាគីដើមចោទ ជាហេតុនាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីដើមចោទយ៉ាងធ្ងន់ធ្ងរ ដោយហេតុថាភាគីដើមចោទនៅពេលទទួលបានប្រាក់កក់រួចហើយ ភាគីដើមចោទបានយកប្រាក់ដែលភាគីចុងចម្លើយកក់ ទៅកក់ដីមួយកន្លែងផ្សេងទៀត។

៣. ការអះអាងរបស់គូភាគី

៣.១. ការអះអាងរបស់ដើមចោទ

១.ខ្លួនបានលក់ដីទៅឱ្យឈ្មោះ [redacted] សុខលីម ក្នុងតម្លៃ ៣០$ ក្នុងមួយម៉ែត្រការ៉េ លើទំហំដី ៤៥៣២ ម៉ែត្រការ៉េ ដោយភាគីចុងចម្លើយបានប្រគល់ប្រាក់កក់ចំនួន ១៥០០០$ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក តាមកិច្ចសន្យាទិញលក់ដី ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៩ បន្ថែមលើកទីពីរ ចំនួន ២០០០០$ (ពីរម៉ឺន) ដុល្លារអាមេរិក តាមលិខិតប្រគល់ទទួលប្រាក់លក់ទិញអចលនវត្ថុ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩។ បន្ទាប់ពីបានប្រាក់កក់លើកទី២មកឈ្មោះ [redacted] សុខលីម ដោយមានលោក [redacted] ដារ៉ា ជាតំណាងបានសន្យាថា និងប្រគល់ប្រាក់ផ្តាច់ទាំងអស់នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩ បើដល់ថ្ងៃកំណត់មិនប្រគល់ប្រាក់គ្រប់ចំនួនទេនោះ ត្រូវជាច់ប្រាក់កក់ជាស្ថាពរ ហេតុនេះខ្លួនសុំរំលាយកិច្ចសន្យា ដោយសារភាគីចុងចម្លើយមិនព្រមប្រគល់ប្រាក់គ្រប់ចំនួនតាមខ្លឹមសារកិច្ចសន្យា។

២.ខ្លួនសុំទាមទារសំណងជម្ងឺចិត្តជាប្រាក់ចំនួន ៣៥០០០$ (បីម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ដោយសារខ្លួនបានយកប្រាក់មួយចំនួនទៅកក់ថ្លៃដីអ្នកផ្សេងដែរ។

៣.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

៣.២ ការអះអាងរបស់ចុងចម្លើយ

មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយធ្វើសេចក្តីថ្លែងការណ៍ក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថាសុំរក្សាសេចក្តីថ្លែងការណ៍ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០ ទុកជាបានការដដែល និងសុំឆ្លើយតបទៅនឹងសេចក្តីថ្លែងការណ៍របស់ដើមចោទ ដូចដែលបានទាមទារនៅក្នុងពាក្យបណ្តឹង ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ដូចខាងក្រោម៖

១.សុំច្រានចោលការទាមទារសុំរំលាយកិច្ចសន្យាទិញលក់ដី ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៩ ដោយសារនៅក្នុងកិច្ចសន្យាទិញលក់ដីនោះ ត្រង់ចំណុចទី៣ បានចែងអំពីកាតព្វកិច្ចរបស់ភាគីអ្នកលក់ដែលមានកាតព្វកិច្ចធ្វើការផ្ទេរសិទ្ធិកាន់កាប់ អោយទៅភាគីអ្នកទិញត្រឹមត្រូវតាមច្បាប់ ដល់មន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ក្រោយពីទទួលបានប្រាក់កក់ពីភាគីអ្នកទិញ ប៉ុន្តែភាគីអ្នកលក់ជាដើមបណ្តឹងមិនបានបំពេញកាតព្វកិច្ចអ្វីទាំងអស់ រហូតដល់ពេលបច្ចុប្បន្ននេះហើយថែមទាំងនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ ភាគីអ្នកលក់ក៏បានធ្វើការស្នើសុំអោយភាគីអ្នកទិញ ជាកូនក្តីរបស់ខ្ញុំបាទ បន្ថែមថ្លៃដីជូនគាត់ចំនួន ២០០០០$ (ពីរម៉ឺន) ដុល្លារអាមេរិក បន្ថែមទៀត ប៉ុន្តែគាត់នៅមិនបំពេញកាតព្វកិច្ចដដែល បើទោះបីកូនក្តីខ្ញុំបាទបានអះអាងក្នុងលិខិតផ្ទេរសិទ្ធិថា ចំពោះការចំណាយទៅលើការផ្ទេរសិទ្ធិ និងការអនុវត្តកាតព្វកិច្ចបង់ពន្ធតាមច្បាប់នេះជាបន្ទុករបស់អ្នកទិញយ៉ាងក៏ដោយ ក៏ភាគីអ្នកលក់មិនព្រមអនុវត្តកាតព្វកិច្ច

Scanned with CamScanner

ដដែល ក្នុងនោះភាគីអ្នកលក់បានអះអាងក្នុងលិខិតផ្ទេរសិទ្ធិនោះផងដែរថា ក្នុងករណីមិនគោរពតាមការអះអាងខាងលើ គាត់សុំទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។ បើទោះបីជាមានការអះអាងយ៉ាងណាក៏ដោយភាគីអ្នកលក់មិនអនុវត្តកាតព្វកិច្ចដដែល ជាងនេះទៅទៀតកូនក្តីខ្ញុំបាទបានស្នើសុំឱ្យភាគីអ្នកលក់ចូលមកទទួលប្រាក់ថ្លៃដីគ្រប់ចំនួន ក៏គាត់មិនព្រមទទួលដែរ ហើយថែមទាំងធ្វើការប្តឹងកូនក្តីខ្ញុំបាទទៅស្នងការដ្ឋាននគរបាលខេត្តកណ្តាល នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៩ ចោទប្រកាន់កូនក្តីខ្ញុំបាទពីបទ រំលោភលើសេចក្តីទុកចិត្ត ទាក់ទងនឹងកិច្ចសន្យា។ ជាងនេះទៅទៀតនៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០ កូនក្តីខ្ញុំបាទបានដាក់ពាក្យស្នើសុំអន្តរាគមន៍ទៅអាជ្ញាធរ ដើម្បីអញ្ជើញភាគីអ្នកលក់មកទទួលប្រាក់ថ្លៃដី តែភាគីអ្នកលក់មិនបានមកចូលរួមនោះទេ។

២.សុំច្រានចោលចំពោះការទាមទារសំណងជម្ងឺចិត្តចំនួន ៣៥០០០$ (បីម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ពីព្រោះកូនក្តីខ្ញុំបាទមិនបានប្រព្រឹត្តបំពានឬប៉ះពាល់ដល់ការអនុវត្តកិច្ចសន្យានោះទេ។

៣.សុំច្រានចោលបន្ទុកទទួលខុសត្រូវលើប្រាក់ប្រដាប់ក្តីនោះឡើយ ពីព្រោះកូនក្តីខ្ញុំបាទមិនបានប្រព្រឹត្តដូចការចោទប្រកាន់របស់ដើមចោទឡើយ។

**៤.ចំណុចវិវាទ និងចំណុចគ្មានវិវាទ**

៤.១ចំណុចវិវាទៈ

តើភាគីដើមចោទមានកំហុស ឬមានការបំពារបំពានកិច្ចសន្យា ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៩ ដែរឬទេ?

៤.២ចំណុចគ្មានវិវាទៈគ្មាន

## <u>សំអាងហេតុ</u>

**តាមលទ្ធផលនៃការសាកសួរសាមីភាគី និងពិនិត្យភស្តុតាងនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថាៈ**

១-មូលហេតុនៃការទាមទាររបស់ដើមចោទ មានលក្ខណៈសមស្របដែលអាចឱ្យតុលាការលើកយកមកធ្វើការពិចារណាបាន។

២.នៅក្នុងនីតិវិធីត្រៀម ក៏ដូចជាក្នុងនីតិវិធីទាញទាញហេតុផលដោយផ្ទាល់មាត់ឃើញថាដើមចោទនិងចុងចម្លើយពិតជាបានបង្កើតកិច្ចសន្យាលក់ទិញដី ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៩ ពិតប្រាកដមែនដោយភាគីចុងចម្លើយបានប្រគល់ប្រាក់កក់ចំនួន ១៥០០០$ តាមកិច្ចសន្យាទិញលក់ដី ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៩ បន្ថែមលើកទីពីរចំនួន ២០០០០$ (ពីរម៉ឺន) ដុល្លារអាមេរិក តាមលិខិតប្រគល់ទទួលប្រាក់ថ្លៃលក់ទិញអចលនវត្ថុ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩។ បន្ទាប់ពីបានប្រាក់កក់លើកទី២ មកឈ្មោះ [redacted] សុខលីម ដោយមានលោក [redacted] ដារ៉ា ជាតំណាងបានសន្យាថា នឹងប្រគល់ប្រាក់ផ្តាច់ទាំងអស់នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩ បើដល់ថ្ងៃកំណត់មិនប្រគល់ប្រាក់គ្រប់ចំនួននោះទេ ត្រូវដាច់ប្រាក់កក់ជាស្ថាពរ លុះដល់ថ្ងៃកំណត់ដែលត្រូវប្រគល់ប្រាក់ចុងចម្លើយបែរជាមិនបានអនុវត្តកាតព្វកិច្ចទៅវិញ។

៣.ក្នុងការពិនិត្យភស្តុតាង និងការសាកសួរសាក្សីឃើញថាៈ

៣.១ឆ្លងតាមការសាកសួរសាក្សីឈ្មោះ [redacted] សំអាត បានឆ្លើយថាកាលពីថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៩ អ៊ុំខ្លួនបានធ្វើកិច្ចសន្យាទិញលក់ដី តែខ្លួនមិនដឹងលក់មួយម៉ែត្រការ៉េប៉ុន្មានទេ នៅពេលធ្វើកិច្ចសន្យាខ្លួននៅជិតនឹង តែខ្លួនអត់ដឹងទេ ។

៣.២ឆ្លងតាមការសាកសួរសាក្សីឈ្មោះ [redacted] ប៊ួយ បានឆ្លើយថាខ្លួនត្រូវជាក្មួយប្រសារ ពូខ្លួនបានលក់ដីដោយធ្វើកិច្ចសន្យាលើកទី១នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៩ ហើយគាត់ប្រាប់ថាគេមកប្រគល់លុយ។

៣.៣ឆ្លងតាមការសាកសួរសាក្សីឈ្មោះ [redacted] ណោត បានឆ្លើយថាខ្លួនដឹងថាគាត់ទទួលប្រាក់ចំនួន ៣៥០០០$ (បីម៉ឺនប្រាំពាន់) ដុល្លារអាមេរិក នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ គេសុំពន្យាពេលមួយខែទៅ

Scanned with CamScanner

ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩ គាត់និយាយគ្នាថាបើដល់ថ្ងៃកំណត់ប្រគល់លុយគ្រប់ ២០០០០$ (ពីរម៉ឺន) ដុល្លារអាមេរិក ។

៣.៤ឆ្លងតាមការសាកសួរសាក្សីឈ្មោះ [redacted] ស៊ីនឿន បានឆ្លើយថានៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩ បើដល់ថ្ងៃប្រគល់លុយគ្រប់ចំនួនមិនប្រគល់នឹងដាច់ប្រាក់កក់ ប្រធានភូមិអ្នកប្រាប់។

៣.៥ឆ្លងតាមការសាកសួរសាក្សីឈ្មោះ [redacted] សុភ័ក្រ្ត បានឆ្លើយថាខ្លួនដឹងរឿងលក់ដីប្រគល់លុយលើកទី២នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ ពេលនោះខ្លួនអត់បានចាំទេ។

៣.៦ឆ្លងតាមការសាកសួរសាក្សីឈ្មោះ [redacted] ទៀន បានឆ្លើយថាពេលប្រគល់លុយចុងក្រោយចំនួន ២០០០០$ (ពីរម៉ឺន) ដុល្លារអាមេរិក បើមិនប្រគល់លុយចុងក្រោយដាច់ប្រាក់កក់។

៣.៧ឆ្លងតាមការសាកសួរសាក្សីឈ្មោះ [redacted] ចិន្តា បានឆ្លើយថាខ្លួនត្រូវជាក្មួយខ្លួនដឹងថាគាត់លក់ដីអោយឈ្មោះ [redacted] សុខលីម ពន្យាពេលបង់ប្រាក់អោយដល់ពេលនឹងបើអត់ប្រគល់លុយគ្រប់ដាច់ប្រាក់កក់។ ខ្លួនអត់ដឹងទេ។

៣.៨ឆ្លងតាមការសាកសួរសាក្សីឈ្មោះ [redacted] ប៉េងឡុង បានឆ្លើយថាពេលយកលុយចុងក្រោយថែមលុយ៥០ភាគរយ ខ្លួនឃើញក្នុងឯកសារនៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩។ខ្លួនបាននិយាយថាយកលុយទៅ ២០០០០$ (ពីរម៉ឺន) ដុល្លារអាមេរិក គាត់ថាយកលុយបង្គ្រាប់នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩ យកទៅខ្លួនជួយដឹងឮ។

៣.៩ឆ្លងតាមការសាកសួរសាក្សីឈ្មោះ [redacted] នន់ បានឆ្លើយថាខ្លួនអ្នកសរសេរកិច្ចសន្យាលិខិតទី១ប្រគល់លុយនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៩ ចំនួន ១៥០០០$ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក និងលើកទី២ចំនួន ២០០០០$ (ពីរម៉ឺន) ដុល្លារអាមេរិក ភាគីបានព្រមព្រៀងគ្នាពេលណាចាក់ផ្លូវនៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩ ប្រគល់លុយគ្រប់ពេលណាធ្វើផ្លូវហើយ ម៉េង ម៉ៅបើកផ្លូវឱ្យដឹក។

៣.១០ឆ្លងតាមការសាកសួរសាក្សីឈ្មោះ [redacted] សុគន្ធា បានឆ្លើយថាខ្លួននិងក្រុមការងារបានយកលុយចំនួន ២០០០០$ (ពីរម៉ឺន) បានសន្យាឱ្យលុយគ្រប់ឈ្លូសឆាយអោយលុយគ្រប់ ខ្លួនបានជូនដំណឹងតាមរយៈមេភូមិ អ្នកទិញចាត់អ្នកលក់ឱ្យរត់ច្បាប់។

៣.១១ឆ្លងតាមការសាកសួរសាក្សីឈ្មោះ [redacted] ហ៊ី បានឆ្លើយបានចូលប្រគល់លុយ ២០០០០$ (ពីរម៉ឺន) ដុល្លារអាមេរិក សន្យាថានៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩ ប្រគល់លុយគ្រប់ចាក់ដី។

៤.តើភាគីដើមចោទមានកំហុស ឬមានការបំពារបំពានកិច្ចសន្យា ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៩ ដែរឬទេ?

-យោងតាមចំណុចទី២, ២.១, ២.២, ៣, ៣.១, ៣.២, ៣.៣ តុលាការយល់ឃើញថាការខកខានមិនបានអនុវត្តកាតព្វកិច្ចរបស់ចុងចម្លើយមានរយៈពេលគិតចាប់ពីថ្ងៃបន្ថែមប្រាក់លើកទីពីរចំនួន ២០០០០$ (ពីរម៉ឺន) ដុល្លារអាមេរិក រហូតដល់ថ្ងៃដែលដើមចោទបានដាក់ពាក្យប្តឹងសុំរំលាយកិច្ចសន្យា គឺចុងចម្លើយមានចេតនាគេចវេសក្នុងការអនុវត្តកិច្ចសន្យាដោយមិនឱ្យសម្រេចគោលបំណងនៃការបង្កើតកិច្ចសន្យា ត្រូវចាត់ទុកជាការបំពានកិច្ចសន្យា និងចាត់ទុកជាកំហុសធ្ងន់ ដូចដែលមានចែងក្នុងមាត្រា ៤០៧, ៤០៨ នៃក្រមរដ្ឋប្បវេណី គប្បីតុលាការពិចារណាពីការស្នើសុំរំលាយកិច្ចសន្យារបស់ចុងចម្លើយ។

៥.ស្របតាមបញ្ញត្តិមាត្រា ៤១១ នៃក្រមរដ្ឋប្បវេណីអានុភាពនៃការរំលាយកិច្ចសន្យាគឺអាចឱ្យភាគីរួចផុតពីករណីយកិច្ចនៃកិច្ចសន្យា ប៉ុន្តែត្រូវមានករណីយកិច្ចសងការខូចខាត។ ភាគីដើមចោទឈ្មោះ [redacted] ម៉ៅ បានទាមទារឱ្យភាគីចុងចម្លើយសងការខូចខាតចំនួន ៣៥០០០$ (បីម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ដែលកើតមកពីការបំពារបំពានកិច្ចសន្យារបស់ចុងចម្លើយឈ្មោះ [redacted] សុខលីម ទទួលស្គាល់ថាដើមចោទ

Scanned with CamScanner

ពិតជាបានទទួលនូវការខាតបង់ប្រាកដមែន ដែលបណ្ដាលមកពីការយឺតយ៉ាវមិនបំពេញកាតព្វកិច្ចរបស់ចុងចម្លើយ គប្បីតុលាការពិចារណាត្រង់ចំណុចនេះផងដែរ។

៦.ចំពោះបន្ទុកនៃប្រាក់បន្ទុកក្ដី តុលាការនឹងសម្រេចតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**<u>សេចក្ដីសម្រេចបញ្ចប់</u>**

១-រំលាយកិច្ចសន្យាទិញលក់ដី ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៩ ចោលជាអសារបង់។

២-បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] សុខលីម សងការខូចខាតចំនួន ៣៥០០០$ (បីម៉ឺនប្រាំពាន់) ដុល្លារអាមេរិក មកឱ្យដើមចោទឈ្មោះ [redacted] ម៉ៅ។

៣-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

សាលក្រមនេះ ទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២១ និងប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១។

-ទុកសិទ្ធិប្ដឹងតវ៉ាតាមកំណត់ច្បាប់។

**ចៅក្រម**

ហត្ថលេខា និងត្រា: [redacted]

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃចន្ទ១២កើត ខែបឋមសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

កណ្ដាល,ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១

បានឃើញ

**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]

បានទទួលភាគដ៏ខ្លួនឈ្មោះ [redacted] សុខលីម។

ថ្ងៃទី 28-មិថុនា-2021

[redacted]